**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2011, 12:48
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់គ្រប់គ្រងការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម និល ណុន

ចៅក្រម យូរ ឧត្ដារា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

---

ចៅក្រមបម្រុង ធូ មណី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្តី") លោក **អៀង សារី** សូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង Susan Lamb រក្សាការប្រាស្រ័យទាក់ទងការងារដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ សំណើនេះមានភាពចាំបាច់ដោយហេតុថា មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង បាននឹងកំពុងប្រាស្រ័យទាក់ទងការងារ *តែម្ខាង* (*ex parte*) ជាមួយតែភាគីមួយចំនួនប៉ុណ្ណោះ ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗសម្រាប់ភាគីទាំងអស់។

## I. ប្រវត្តិ

១. កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ លោក Michael G. Karnavas សហមេធាវីអន្តរជាតិនៃក្រុមមេធាវីការពារក្តីបានផ្ញើសារអេឡិចត្រូនិកមួយ ទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងបានចម្លងជូនភាគីទាំងអស់ ដែលមានខ្លឹមសារជាអាទិ៍ថា៖

> យើងយល់ថាលោកស្រីបានប្រាប់បុគ្គលមួយចំនួនថា នាពេលឆាប់ៗខាងមុខ យើងនឹងបានទទួលដីកាកំណត់កាលបរិច្ឆេទសវនាការមួយដែលកំណត់យកថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជាថ្ងៃធ្វើសវនាការលើអង្គសេចក្តី។ យើងក៏បានឮពាក្យចចាមអារ៉ាមទៀតថា សេចក្តីសន្និដ្ឋានចោទប្រកាន់ ទំនងជាធ្វើនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ដើម្បីឱ្យមានតម្លាភាព ជាពិសេសដោយសារមានការរិះគន់ជាហូរហែរមកលើ អ.វ.ត.ក (ភាគច្រើនហាក់ដូចជាដោយសារការបែកធ្លាយព័ត៌មានផ្ទៃក្នុង) ទើបយើងចង់ឱ្យមានដីកាកំណត់កាលបរិច្ឆេទត្រឹមត្រូវដែលមានហត្ថលេខារបស់ចៅក្រមប្រធាន ឬយ៉ាងហោចណាស់ជាសារអេឡិចត្រូនិកដែលគ្រាន់តែជូនដំណឹងជាមុនពីលោកស្រី ដែលជូនដំណឹងឱ្យភាគីទាំងអស់បានជ្រាប។ ខ្ញុំគិតថា ការចែករំលែកព័ត៌មានដល់មនុស្សមួយចំនួនក្នុងលក្ខណៈក្រៅផ្លូវការ វាមិនជួយភាគីមានទំនុកចិត្តលើកិច្ចដំណើរការនីតិវិធីឡើយ។ ខ្ញុំសូមអភ័យទោសចំពោះការដែលខ្ញុំលើកឡើងដោយចំៗបែបនេះ។ ខ្ញុំជឿថាលោកស្រីនឹងយល់អំពីកង្វល់របស់ខ្ញុំ ដោយសារយើងមានបញ្ហាសំខាន់ៗជាច្រើននៅក្នុងសំណុំរឿងនេះ

ដែលត្រូវដោះស្រាយឲ្យបានមុនពេលចាប់ផ្តើមសវនាការ ហើយខ្ញុំពុំចូលចិត្តការប្រាស្រ័យទាក់ទងជាមួយភាគី *តែម្ខាង (ex parte)* ឡើយ[1] ។

២. មិនយូរប៉ុន្មានក្រោយពេលមេធាវីការពារក្តីបានផ្ញើសារអេឡិចត្រូនិកខាងលើនេះចេញ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងក៏បានផ្ញើសារអេឡិចត្រូនិកមួយទៅភាគីទាំងអស់ ដោយជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ[2]។ នៅថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់បានឆ្លើយតបដាច់ដោយឡែកមួយទៅលោក Karnavas តាមរយៈសារអេឡិចត្រូនិកដែលមានខ្លឹមសារថា៖

> សារអេឡិចត្រូនិកមួយដែលផ្តល់សេចក្តីសង្ខេបលម្អិតលើបញ្ហាទាំងអស់ ពាក់ព័ន្ធនឹងការរៀបចំសវនាការដំណាក់កាលដំបូង ត្រូវបានផ្ញើទៅភាគីទាំងអស់កាលពីព្រឹកមិញ។ មុនពេលចេញលិខិតនេះបន្តិច ព័ត៌មានមួយចំនួននៅក្នុងលិខិតនោះត្រូវបានចែករំលែកដោយសម្រិតសម្រាំងទៅបុគ្គលមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍ ប្រធានស្តីទីនៃផ្នែកគាំពារការការពារក្តី អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងអង្គភាព ឬមន្ត្រីសំខាន់ផ្សេងៗ) ដែលអាចជួយដល់ប្រសិទ្ធភាពនៃការរៀបចំសវនាការ។ នាងខ្ញុំធ្លាប់បានបញ្ជាក់ថា នាងខ្ញុំគឺជាជនបង្គោលសម្រាប់ការប្រាស្រ័យទាក់ទងរវាងភាគី និងអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុ សូមលោកមេត្តាកុំផ្ញើលិខិតប្រភេទនេះដោយចម្លងជូនទៅក្រុមអង្គជំនុំជម្រះសាលាដំបូង[3]។

៣. លោក Karnavas បានឆ្លើយតបទៅវិញថា៖

---

[1] សារអេឡិចត្រូនិករបស់លោក Karnavas ស្តីពី "កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងបានចម្លងជូនភាគីទាំងអស់។

[2] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅភាគទាំងអស់ដែលមានចំណងជើងថា "លិខិតផ្ញើទៅភាគីក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបើក និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ និងការជូនដំណឹងមុនពេលសវនាការនៅថ្ងៃទី ១៩-២០ ខែ តុលា ឆ្នាំ ២០១១" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

[3] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅលោក Karnavas និងចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

សូមអរគុណដែលលោកស្រីបានធ្វើការឆ្លើយតបបានឆាប់រហ័ស។ នៅក្នុងលិខិតរបស់លោកស្រី ពាក្យសំខាន់គឺពាក្យថា "សម្រិតសម្រាំង"។ លោក អាង ឧត្តម និង ខ្ញុំ ជាតំណាងរបស់លោក អៀង សារី។ ឬនិយាយម្យ៉ាងទៀតថា យើងជាភាគី។ ទោះបីអង្គភាពគាំពារការការពារក្តីមានមុខងារសំខាន់ខ្លាំងយ៉ាងណាក៏ដោយ ក៏អង្គភាពនេះពុំមែន ពុំអាចហើយក៏នឹងពុំតំណាងឲ្យលោក អៀង សារី បានឡើយ ហើយ "បុគ្គលមួយចំនួនតូច" ដែលលោកស្រីជ្រើសរើស "សម្រិតសម្រាំង" នោះក៏ពុំតំណាងឲ្យលោក អៀង សារី ដែរ។ ដូច្នេះ នេះហើយជាកង្វល់របស់ខ្ញុំ។ ខ្ញុំសូមអភ័យទោសចំពោះការធ្វើឲ្យរំខានដល់អង្គជំនុំជម្រះសាលាដំបូងលើបែបនេះ ក៏ប៉ុន្តែ ខ្ញុំយល់ថាជាការចាំបាច់ដែលត្រូវឲ្យពួកគាត់បានដឹងអំពីបញ្ហានេះ[4]។

៤. កាលពីថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១ មេធាវីការពារក្តីបានទទួលដំណឹងក្រៅផ្លូវការពីសំណាក់មេធាវីការពារក្តីម្នាក់ថា មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជួបទាក់ទងជាមួយក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន និងបានជូនដំណឹងពួកគាត់អំពីក្រុមអ្នកជំនាញ និងសាក្សីបន្ទាប់ដែលអង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាកោះហៅ។ បន្ទាប់ពីបានទទួលព័ត៌មាននេះភ្លាម មេធាវីការពារក្តីបានផ្ញើសារអេឡិចត្រូនិក ទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយបានចម្លងជូនភាគី ដើម្បីសាកសួរថាតើព័ត៌មាននេះត្រឹមត្រូវដែរឬទេ ពិសេសថាតើលោកស្រី

[4] សារអេឡិចត្រូនិករបស់ Mr. Karnavas ទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងបានចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងសារអេឡិចត្រូនិកនេះថា "នាងខ្ញុំអាចបញ្ជាក់ជូនលោកថាភាគីទាំងអស់បានទទួលការជូនដំណឹងអំពីបញ្ហាពាក់ព័ន្ធទាំងអស់បានឆាប់រហ័ស ហើយពុំមានភាគីណាមួយខូចប្រយោជន៍ដោយសារការកំហិតព័ត៌មាននាពេលកន្លងមកដែលនាងខ្ញុំបានលើកឡើងនោះឡើយ (ដែលបានកើតឡើងមុនពេលសាររួមផ្ញើទៅភាគីទាំងអស់)"។ សារអេឡិចត្រូនិកទីពីររបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើមកលោក Karnavas និងបានចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។

អាចជូនដំណឹងទៅភាគីថាតើអ្នកជំនាញដែលមានអត្តលេខ TCE 38 បានយល់ព្រមផ្តល់ភស្តុតាងដែរឬទេ[5]។

៥. កាលពីថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបយ៉ាងដូច្នេះថា៖

> សាក្សីទាំងប៉ុន្មានខាងក្រោមកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះសម្រាប់សវនាការដំណាក់កាលបន្ទាប់។ សាក្សីទាំងនេះត្រូវបាន ក.ស.ព មេធាវីការពារក្តី នួន ជា និង ខៀវ សំផន កោះហៅរៀងៗខ្លួន។ នាងខ្ញុំបានទាក់ទងជាមួយក្រុមមេធាវីការពារក្តីទាំងពីរខាងលើដើម្បីសាកសួរថាតើពួកគេចាប់អារម្មណ៍ក្នុងការសួរសំណួរសាក្សីទាំងនេះដែរឬទេ។
>
> អង្គជំនុំជម្រះនឹងសម្រេចថាតើខ្លួននឹងត្រូវកោះហៅសាក្សី និងអ្នកជំនាញណាម្នាក់ឲ្យចូលខ្លួននៅសវនាការដំណាក់កាលបន្ទាប់ ហើយតើត្រូវប្រគល់ភារកិច្ចក្នុងការសួរសំណួរទៅភាគីណានៅពេលឆាប់ៗខាងមុខ។ ភាគីនឹងទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចទាំងអស់នេះឆាប់ៗតាមដែលអង្គជំនុំជម្រះអាចធ្វើទៅបាន[6]។

៦. មេធាវីការពារក្តីបានឆ្លើយតបវិញថា៖

> លោក អាង ឧត្តម និងលោក Karnavas សូមបញ្ជាក់ជាថ្មី (សូមពិនិត្យសារអេឡិចត្រូនិករបស់លោក Karnavas ផ្ញើទៅលោកស្រីកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១) អំពីការព្រួយបារម្ភអំពីការដឹងព័ត៌មានពីប្រភពដទៃថា មានការប្រាស្រ័យទាក់ទងការងាររវាងលោកស្រី និងក្រុមមេធាវីការពារក្តីផ្សេងពាក់ព័ន្ធនឹងសាក្សី និងបញ្ហាកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃមុខ។ ភាគីទាំងអស់ត្រូវទទួលបានការជូនដំណឹង

---

[5] សារអេឡិចត្រូនិករបស់ Tanya Pettay ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងបានចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង", ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

[6] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ផ្ញើមកលោកស្រី Pettay ចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "ពាក់ព័ន្ធនឹង៖ ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១។

ពោលគឺពុំមែនតែភាគីមួយចំនួនតូចប៉ុណ្ណោះទេ ទោះបីពួកគេពុំអាចជាអ្នកសួរសំណួរក៏ដោយ។ ប្រសិនបើមានហេតុផលណាមួយដែលលោកស្រីយល់ថាចាំបាច់ដែលត្រូវបន្តការប្រាស្រ័យទាក់ទងជាមួយតែភាគីមួយចំនួន សូមបញ្ជាក់អំពីមូលហេតុដើម្បីយើងអាចដាក់អ្វីមួយទៅអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងទង្វើដែលគ្មានតម្លាភាពបែបនេះ។ នៅឯតុលាការផ្សេងឯទៀត ក៏ពុំធ្លាប់មានការប្រាស្រ័យទាក់ទងការងារជាមួយភាគីតែម្ខាងបែបនេះដែរ[7]។

៧. មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបថា៖

នាងខ្ញុំសូមបញ្ជាក់ច្បាស់ថា ការប្រាស្រ័យទាក់ទងការងារដែលលោកបានលើកឡើងពុំពាក់ព័ន្ធនឹងមេធាវីការពារក្តី អៀង សារី ឬភាគីណាមួយផ្សេងដែលមានបញ្ជាក់ក្នុងសារអេឡិចត្រូនិកនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការចាត់តាំងភារកិច្ចទទួលខុសត្រូវក្នុងការសួរសំណួរទៅភាគីតាមការសមស្រប និងមនុស្សដែលអាចក្លាយជាសាក្សីក្រោមការពិចារណា ត្រូវបានដាក់បញ្ចូលតែក្នុងបញ្ជីសាក្សីរបស់ ក.ស.ព និងក្រុមមេធាវីការពារក្តីចំនួន ២ ក្រុមប៉ុណ្ណោះ។ ជំហានដំបូងក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះគឺដើម្បីបញ្ជាក់ថាតើក្រុមមេធាវីការពារក្តីទាំង ២ នេះ ឬ ក.ស.ព អាចមានឆន្ទៈបំពេញភារកិច្ចនេះដែរឬទេ។ មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ឬភាគីណាមួយផ្សេង ពុំអាចបញ្ចេញយោបល់ពាក់ព័ន្ធនឹងបញ្ហាថាតើ នួន ជា ឬ ខៀវ សំផន មានបំណងសួរសាក្សីដែលមានឈ្មោះក្នុងបញ្ជីឈ្មោះសាក្សីរបស់ពួកគេទេ។ ជាការត្រឹមត្រូវដែលលោកមានប្រសាសន៍ថា នៅតុលាការដទៃទៀត មិនមែនបុគ្គលទាំងអស់ដែលស្ថិតក្នុងតួនាទីរបស់នាងខ្ញុំ សុទ្ធតែចាត់វិធានការបង្ការជាមុនពាក់ព័ន្ធ

---

[7] សារអេឡិចត្រូនិករបស់លោកស្រី Tanya Pettay ផ្ញើទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថាដែលមានចំណងជើងថា "ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

នឹងការរៀបចំសវនាការដូចនាងខ្ញុំកំពុងធ្វើឡើយ។ កិច្ចការនេះផ្តល់ជាប្រយោជន៍ក្នុងក្របខណ្ឌការរៀបចំប្រកបដោយប្រសិទ្ធភាព និងជាប្រយោជន៍ដល់ភាគី[8]។

៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយតបទៅនឹងបណ្តុំសារអេឡិចត្រូនិកនេះ ដើម្បីជូនដំណឹងទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ ថាខ្លួនសូមអរគុណដែលបានទទួលការជូនដំណឹង អំពីការប្រាស្រ័យទាក់ទងការងារនេះ "ដើម្បីយល់អំពីលក្ខណៈសម្បត្តិដែលអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ក្នុងការចាត់តាំងភារកិច្ចទទួលខុសត្រូវចម្បងទៅភាគីសម្រាប់ការសួរសំណួរ និងដើម្បីតម្លាភាព"[9]។

៩. កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការមួយជាមួយភាគី។ នៅក្នុងអង្គប្រជុំនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចម្លងជូនភាគីទាំងអស់នៅក្នុងលិខិតប្រាស្រ័យទាក់ទងការងារពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ខ្លួននឹងពុំធ្វើដូច្នេះឡើយ ពោលគឺគ្រាន់តែចម្លងជូនភាគីដែលខ្លួនយល់ថាពាក់ព័ន្ធប៉ុណ្ណោះ។ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា ការចម្លងជូនភាគីទាំងអស់ នឹងបង្កើតឲ្យការងាររវល់ច្រើនសម្រាប់ខ្លួនពីព្រោះនៅពេលខ្លួនផ្ញើសារអេឡិចត្រូនិករួមមួយទៅភាគីទាំងអស់ ខ្លួននឹងទទួលសារអេឡិចត្រូនិកតបជាច្រើន និងបង្កើតឲ្យមានបន្ទុកការងារច្រើន។

## II. ច្បាប់

១០. ចំពោះច្បាប់ជាធរមាន និងក្រមសីលធម៌ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងការងារជាមួយ*ភាគីតែម្ខាង (ex parte)* សូមពិនិត្យមើលសំណើរបស់ អៀង សារី សុំឲ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធ

[8] សារអេឡិចត្រូនិកទីពីររបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅលោកស្រី Pettay, ចម្លងជូនភាគីទាំងអស់ដែលមានចំណងជើងថា "ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១១។

[9] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់តំណាងដើមបណ្តឹងរដ្ឋប្បវេណី Jeanne Sulzer ផ្ញើទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចម្លងជូនភាគីទាំងអស់ ដែលមានចំណងជើងថា "ពាក់ព័ន្ធនឹង៖ ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

នឹងការប្រាស្រ័យទាក់ទងការងារជាមួយភាគីតែម្ខាងរវាងសហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម Cartwright និងភាគីផ្សេងៗ[10] និងបណ្តឹងលើកទី២ដោយអនុលោមតាមវិធាន ៣៤ របស់ អៀង សារី ប្តឹងជិតចិត្តចៅក្រម Marcel LEMONDE និងការចូលរួមជាមួយពាក្យបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្តឹងជិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឲ្យមានសវនាការមួយជាសាធារណៈ[11]។

## III. សំណើ

១១. ដើម្បីលើកកម្ពស់តម្លាភាព មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងចម្លងជូនភាគីទាំងអស់ ទៅក្នុងលិខិតប្រាស្រ័យទាក់ទងការងារក្រៅផ្លូវការរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។ ការធ្វើបែបនេះនឹងលើកកម្ពស់តម្លាភាព និងជួយធានាថា ភាគីទាំងអស់ទទួលបានការយកចិត្តទុកដាក់ដូចៗគ្នា។ ជាងនេះទៅទៀត ការធ្វើបែបនេះនឹងពុំធ្វើភាគីណាមួយខូចប្រយោជន៍ឡើយ។

១២. ការប្រាស្រ័យទាក់ទងការងារជាមួយភាគី *តែម្ខាង* របស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ទោះបីពុំមែនដើម្បីផ្តល់ប្រយោជន៍ ឬធ្វើឲ្យខូចប្រយោជន៍ភាគីណាមួយក្តី ក៏វាធ្វើឲ្យមានការយកចិត្តទុកដាក់មិនស្មើគ្នាចំពោះភាគីផ្សេងៗដែរ។ ទោះត្រូវ ឬខុសក៏ដោយ ការធ្វើបែបនេះ ធ្វើឲ្យមានការមន្ទិលសង្ស័យ ឬការមិនពេញចិត្តជាក់ជាមិនខាន។ ភាគីទាំងអស់មានផលប្រយោជន៍ដូចៗគ្នាក្នុងការកំណត់កាលបរិច្ឆេទសវនាការ និងក្នុងការដឹងថា សាក្សីណាខ្លះដែលអង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាកោះហៅមកផ្តល់សក្ខីកម្មនៅពេលបន្ទាប់ ទោះបីពុំទាន់មានការសម្រេចជាស្ថាពរក្តី។ គ្មានហេតុផលណាមួយដែលមិនត្រូវឲ្យភាគីទាំងអស់បានដឹងអំពីព័ត៌មានដែលមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង បានផ្តល់ទៅភាគីមួយចំនួនឡើយ។ ភាគីដទៃ

---

[10] សំណើរបស់ អៀង សារី សុំឲ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងការងារជាមួយភាគីតែម្ខាង រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រម Cartwright និងមនុស្សដទៃទៀត, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ E137/3។

[11] បណ្តឹងលើកទី២ដោយអនុលោមតាមវិធាន ៣៤របស់អៀង សារី ប្តឹងជិតចិត្តចៅក្រម Marcel LEMONDE និងការចូលរួមជាមួយពាក្យបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្តឹងជិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឲ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, ១។

អាចមានបំណងបញ្ចេញយោបល់ពាក់ព័ន្ធនឹងភាគីណាមួយដែលត្រូវសួរសាក្សីណាម្នាក់ ឬពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទៀត។

១៣. ដោយហេតុថាសំណើរបស់មេធាវីការពារក្តីសុំឱ្យធ្វើលិខិតប្រាស្រ័យទាក់ទងការងារទៅភាគីទាំងអស់ មិនបានទទួលការយកចិត្តទុកដាក់ ហើយដោយសារមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានបដិសេធជាច្រើនដងពុំព្រមស្វែងយល់ ឬទទួលស្គាល់សំណើរបស់មេធាវីការពារក្តី (និងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី) ដើម្បីឱ្យមានតម្លាភាពជាងមុន មេធាវីការពារក្តីពុំមានជម្រើសអ្វីក្រៅពីស្នើដំណោះស្រាយសមស្រប តាមរយៈការលើកបញ្ហានេះជូនទៅអង្គជំនុំជម្រះសាលាដំបូង។

**អាស្រ័យហេតុនេះ** ដូចហេតុផលដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង**បង្គាប់**ឱ្យមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង រក្សាការប្រាស្រ័យទាក់ទងការងាររបស់ខ្លួនដោយចំហរ និងមានតម្លាភាពជាមួយភាគីទាំងអស់ពាក់ព័ន្ធនឹងបញ្ហារៀបចំសវនាការ។

សូមអង្គជំនុំជម្រះទទួលយកសំណើនេះដោយក្តីអនុគ្រោះ។

_______________ _______________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១